# សេចក្តីជូនដំណឹង

## ការបើកកម្មវិធីបណ្តុះបណ្តាលអំពីច្បាប់ស្តីពីការងារសម្រាប់ កម្មករនិយោជិតកាត់ដេរ ឆ្នាំ២០១១

**កាលបរិច្ឆេទ** : ថ្ងៃ អាទិត្យ ទី ១៦ ខែ មករា ឆ្នាំ ២០១១

**វេលាម៉ោង** : ៨ ព្រឹក តទៅ

**ទីកន្លែង** : វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស (សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ តាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ី)

**កម្មវត្ថុ** : *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ នឹងរៀបចំការបណ្តុះបណ្តាលមួយគឺ "ការបណ្តុះបណ្តាលអំពីច្បាប់ស្តីពីការងារសម្រាប់កម្មករនិយោជិតកាត់ដេរឆ្នាំ២០១១" ដល់កម្មករនិយោជិតចំនួន២០០០នាក់ ដែលមកពីរោងចក្រចំនួន៨០ផ្សេងៗគ្នា។ ការបណ្តុះបណ្តាលនេះ នឹងត្រូវធ្វើឡើងនៅរៀងរាល់ថ្ងៃអាទិត្យក្នុងរយៈពេល៤សប្តាហ៍ជាប់ៗគ្នា ដោយចាប់ផ្តើមពីថ្ងៃទី១៦ ខែមករា នេះតទៅ។ នៅរៀងរាល់ថ្ងៃអាទិត្យ កម្មករនិយោជិតចំនួន៥០០នាក់មកពីរោងចក្រចំនួន២០ផ្សេងៗគ្នា នឹងមកចូលរួមការបណ្តុះបណ្តាលនេះ។

ការបណ្តុះបណ្តាលនេះបានទទួលការគាំទ្រពីរោងចក្រកាត់ដេរដែលមានកម្មកររបស់ខ្លួនកំពុងធ្វើការ។ ការបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្តល់ចំណេះដឹងជាមូលដ្ឋានស្តីពីច្បាប់ការងារប្រទេសកម្ពុជា និងព័ត៌មានអំពីសិទ្ធិនិងការទទួលខុសត្រូវរបស់ពួកគេ និងអំពីសុវត្ថិភាពការងារនៅកន្លែងធ្វើការ។

**អ្នករៀបចំ** : ការបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងដោយ*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ ប៉ុន្តែក៏នឹងមានការចូលរួមពីអង្គការមួយចំនួនទៀតដូចជា អង្គការម៉ារីស្រ្តូបអន្តរជាតិ អង្គការ PSF គំរោងHIP ទីភ្នាក់ជាតិនៃមុខរបរ (NEA) ក្រុមហ៊ុនរីង និងក្រុមហ៊ុន ស៊ី អឹម កា (CMK) ដើម្បីចូលរួមផ្សព្វផ្សាយការយល់ដឹងផ្សេងៗនាពេលសម្រាកអាហារថ្ងៃត្រង់។

អង្គការដៃគូទាំងនេះនឹងផ្សព្វផ្សាយព័ត៌មានទៅកាន់កម្មករនិយោជិតអំពីសុខភាពបន្តពូជ ការទទួលបាននូវការថែទាំសុខភាព ឱកាសអភិវឌ្ឍន៍ជំនាញ និងលទ្ធភាពក្នុងការទទួលបាននូវសេវាហិរញ្ញវត្ថុ។

អំឡុងពេលសម្រាកអាហារថ្ងៃត្រង់ កម្មករនិយោជិតអាចទស្សនាការសម្ដែងនូវឈុតអប់រំអំពីរបៀបដើម្បីចៀសផុតពីអំពើហិង្សាក្នុងគ្រួសារ និងរបៀបប្រាស្រ័យទាក់ទងឱ្យកាន់តែប្រសើរ ដែលសម្ដែងដោយក្រុមហ្វារពន្លឺសិល្បៈដែលមកពីខេត្តបាត់ដំបង។ ហើយពួកគេក៏អាចឈ្នះរង្វាន់ ដូចជាម៉ាស៊ីនដេរ និងកង់ជាដើម ក្នុងការចាប់ឆ្នោតផ្សងសំណាង។

យើងខ្ញុំសូមគោរពអញ្ជើញអ្នកសារព័ត៌មានចូលរួមការបើកនូវការបណ្ដុះបណ្ដាលនេះ ដែលនឹងប្រព្រឹត្តធ្វើឡើងនាថ្ងៃ អាទិត្យ ទី ១៦ ខែ មករា ចាប់ពីម៉ោង ៨ ព្រឹកតទៅ នៅវិទ្យាជាតិបណ្ដុះបណ្ដាលបច្ចេកទេស។

| | |
|---|---|
| សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក | លោក ប៊ុន យិញ<br>*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា*<br>នៃអង្គការពលកម្មអន្តរជាតិ (ILO)<br>ទូរស័ព្ទ : ០១២ ៩០២ ៩៩០<br>អ៊ីម៉េល : ying@ilo.org |